# ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ជួបពិភាក្សាការងារ

# ជាមួយឯកឧត្តមអភិបាលរងខេត្ត ហ៊ូណាន ប្រទេសចិន





នៅព្រឹកថ្ងៃទី២៤ ខែ ធ្នូ ឆ្នាំ២០១៤ ឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និង សិប្បកម្ម រួមជាមួយថ្នាក់ដឹកនាំ និងមន្ត្រីជំនាញក្រោមក្រសួង បានទទួលជួបពិភាក្សាការងារជាមួយប្រតិភូខេត្តហូណាន នៃ ប្រទេសចិន ដឹកនាំដោយឯកឧត្តម **He BaoXiang** អភិបាលរងខេត្ត ហ៊ូណាននៃប្រទេសចិន នៅទីស្តីការ ក្រសួងឧស្សាហ-កម្ម និងសិប្បកម្ម ។

ជាកិច្ចចាប់ផ្តើម ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានសម្តែងការស្វាគមន៍ និងលើកឡើងពីទំនាក់ទំនងដ៏យូរអង្វែងរវាងកម្ពុជា-ចិន ហើយបច្ចុប្បន្នបានក្លាយជាដៃគូសហប្រតិបត្តិការយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ ។ ឯកឧត្តម បានចាត់ទុកដំណើរទស្សនៈកិច្ចរបស់ប្រតិភូខេត្តហ៊ូណាន នឹងរិតចំណងបានថែមទៀតនូវទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការលើវិស័យ សេដ្ឋកិច្ច ឧស្សាហកម្ម និងបច្ចេកវិទ្យាផងដែរ ។

ឯកឧត្តម **He BaoXiang** អភិបាលរងខេត្ត ហ៊ូណាននៃប្រទេសចិន បានវាយតម្លៃខ្ពស់ចំពោះភាពរីកចម្រើនយ៉ាងឆាប់រហ័សរបស់កម្ពុជា និងទំនាក់ទំនងដ៏ល្អរវាងកម្ពុជា-ចិន ព្រមទាំងសម្តែងនូវទឹកចិត្តរីករាយចំពោះការបំពេញទស្សនៈកិច្ចជាលើកទី១នៅកម្ពុជា ។ ក្នុងនោះក៏មានវិស័យឯកជនមកពីផ្នែកឧស្សាហកម្ម ពាណិជ្ជកម្ម និងវិនិយោគ ដើម្បីស្វែងយល់និងពិនិត្យលទ្ធភាពការបណ្តាក់ទុននៅកម្ពុជាផងដែរ ។ ឯកឧត្តម អភិបាលខេត្ត បានបង្ហាញពីសក្តានុពលនៃខេត្តហ៊ូណាន ដែលជាខេត្តជង្រុកស្រូវរបស់ចិន មានប្រជាជនប្រមាណ ៧៣លាននាក់ ។ ក្នុងនោះវិស័យឈានមុខគេរបស់ខេត្ត គឺវិស័យឧស្សាហកម្ម សេវាកម្ម និងកសិកម្ម ។ ឯកឧត្តម បានបញ្ជាក់បន្ថែមថាៈទំនាក់ទំនងពាណិជ្ជកម្មរវាងកម្ពុជា និងខេត្តហ៊ូណានគឺមានការកើនឡើងជាលំដាប់ ។ក៏ប៉ុន្តែ នៅក្នុងកំរិតទាបនៅឡើយ ដែលគួរភាគីទាំងពីរប្រើប្រាស់សក្តានុពល និងឱកាសពង្រីកដៃគូ ដើម្បីបំពេញឱ្យគ្នាទៅវិញទៅមកផ្នែកសេដ្ឋកិច្ច ។ ឯកឧត្តម អភិបាលខេត្ត បានបន្តថាៈបច្ចុប្បន្នមានសហគ្រាសមកពីខេត្ត ហ៊ូណាន មកបោះទុនរកស៊ីនៅកម្ពុជា ចំនួន១៥ ក្រុមហ៊ុន សហគ្រាស ។

ឆ្លៀតឱកាសនោះ ឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានជម្រាបជូនពីសក្តានុពលរបស់កម្ពុជា និងកត្តា០៤ យ៉ាង ដែលជាទំនុកចិត្តសម្រាប់អ្នកវិនិយោគទាំងក្នុង និងក្រៅប្រទេស ។ គឺ **ទី១ៈ**ស្ថិរភាពនយោបាយ **ទី២ៈ**ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច **ទី៣ៈ**តម្លាភាពនៃក្របខ័ណ្ឌច្បាប់ដែលអាចប៉ាន់ប្រមាណបាន ដោយកម្ពុជាជាសមាជិកអង្គការ ពាណិជ្ជកម្មពិភពលោក និងសមាជិកអាស៊ាន និង **ទី៤ៈ**កម្ពុជាទទួលបានភាពអនុគ្រោះពាណិជ្ជកម្មពីប្រទេសដៃគូ និងប្រទេសអភិវឌ្ឍន៍ជាច្រើន ដែលអនុញ្ញាតឱ្យទំនិញនាំចេញពីកម្ពុជា រាប់ពាន់មុខ នាំចេញដោយមិនជាប់ពន្ធ និងមិនជាប់កូតា ។

ឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានស្វាគមន៍ និងលើកទឹកចិត្តឱ្យវិស័យឯកជនមកពីខេត្តហ៊ូណានវិនិយោគលើវិស័យអាទិភាពមួយចំនួន ដូចជាៈវិស័យសំណង់ ឧស្សាហកម្ម សេវាកម្ម កសិកម្ម និងទេសចរណ៍ ។ ជាមួយគ្នានេះ ឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** ក៏បានស្នើឱ្យមានកិច្ចសហប្រតិបត្តិការផ្លាស់ប្តូរបទពិសោធន៍លើវិស័យបច្ចេកទេស កសិកម្មដែលខេត្តហ៊ូណានមានជំនាញខ្ពស់លើវិស័យនេះ ជាពិសេសលើវិស័យដាំដុះ និងកែច្នៃអង្ករនាំចេញ ស្របពេលដែលប្រភេទអង្ករផ្កាម្លិះកម្ពុជាជាប់ចំណាត់ថ្នាក់លេខ១ បីឆ្នាំ ជាប់គ្នា ជាអង្ករដែលមានរស់ជាតិឆ្ងាញ់បំផុតលើពិភពលោក ។

ជាចុងក្រោយគូសន្ទនាទាំងពីរ បានលើកទឹកចិត្ត និងពិនិត្យលទ្ធភាពឱ្យមានការផ្លាស់ប្តូរទស្សនៈកិច្ចស្វែងយល់ពីគ្នាទៅវិញទៅមក ក្នុងកំរិតបច្ចេកទេស និងជម្រុញវិស័យជាអាទិភាពមួយចំនួន ។


H.E. Mr. He BaoXiang
H.E. Dr. CHAM PRASIDH
Senior Minister
Minister

